# គណៈកម្មការទ្រទ្រង់សាលារៀន នាំមកនូវទឹកប្រើប្រាស់ដល់សាលារៀនមូលដ្ឋាន

care

សាលារៀនមួយក្នុងខេត្តមណ្ឌលគិរី បានទទួលអត្ថប្រយោជន៍ពីភាពជាម្ចាស់របស់សហគមន៍ នៅពេលគណៈកម្មការទ្រទ្រង់សាលារៀននេះបានរៃអង្គាសប្រាក់ទិញស៊ីទែនទឹកដើម្បីឱ្យសិស្សមានទឹកប្រើប្រាស់។

មុនពេលចូលថ្នាក់រៀន សិស្សានុសិស្សសាលាបឋមសិក្សាដាក់ដាំ បានមកជុំគ្នានៅកន្លែងលាងដៃដើម្បីលាងដៃរបស់ពួកគេ និងបង្ហូរទឹកចូលទៅក្នុងធុងជ័រពេញ។ ទឹកក្នុងធុងជ័រនេះនឹងត្រូវប្រើប្រាស់ដើម្បីស្រោចសួនដែលទើបកសាងថ្មី និងលាងសម្អាតបង្គន់។

នេះជាអ្វីថ្មីដែលមើលឃើញក្នុងពេលថ្មីៗនេះ។ ពីមុនសាលាបឋមសិក្សា ដាក់ដាំ ខេត្តមណ្ឌលគិរីដែលជាខេត្តស្ថិតក្នុងភូមិភាគឦសានគ្មានទឹកប្រើប្រាស់ទេ កន្លែងសម្រាប់សិស្សលាងដៃ និងបង្គន់ភាគច្រើនប្រើប្រាស់មិនកើត។

ទើបតែឆ្នាំនេះទេដែលស៊ីទែនទឹកត្រូវបានដំឡើងនៅជិតអគារសិក្សានៃសាលាបឋមសិក្សា ដាក់ដាំ។

ស៊ុន ម៉ៅ ជានាយកសាលា និងជាទីប្រឹក្សារបស់គណៈកម្មការទ្រទ្រង់សាលាបឋមសិក្សា ដាក់ដាំ និយាថាការអភិវឌ្ឍនេះអាចកើតឡើងបានក៏ដោយសារតែសមាជិកគណៈកម្មការទ្រទ្រង់សាលារៀននេះដែរ។

គាត់រៀបរាប់ថា ៖ "ពេលយើងសម្រេចចិត្តដំឡើងស៊ីទែនទឹកនេះ សាលាគ្មានប្រាក់ ឬថវិកាទេ ដូច្នេះខ្ញុំក៏ទូរសព្ទទៅគណៈកម្មការទ្រទ្រង់សាលារៀន ហើយសុំឱ្យពួកគេទិញឈើខ្លះ និងជួលកម្មករម្នាក់ដែលចេះដំឡើងស៊ីទែនទឹក"។

យោងតាម ស៊ុន ម៉ៅ បានឱ្យដឹងថាដោយសារវគ្គសិក្ខាសាលាបណ្តុះបណ្តាលដែលរៀបចំដោយអង្គការឃែរ សមាជិកគណៈកម្មការបានដឹងពីរបៀបជួយគាំទ្រសាលារៀន។ អំឡុងពេលសិក្ខាសាលាបណ្តុះបណ្តាលទាំងនេះ សមាជិកគណៈកម្មការទ្រទ្រង់សាលារៀនបានដឹងថា ពួកគេគួរចូលរួមក្នុងការគ្រប់គ្រងសាលារៀនក្នុងការសាងសង់សាលារៀន និងក្នុងការជួយរៃប្រាក់សម្រាប់សាងសង់សាលារៀន។

គាត់ពន្យល់ថា៖ "តាមរយៈការបណ្តុះបណ្តាល គណៈកម្មការទ្រទ្រង់សាលារៀនមានភាពកាន់តែសកម្ម និងចូលរួមក្នុងការគ្រប់គ្រងសាលារៀន និងរៃអង្គាសប្រាក់សម្រាប់សាលារៀនជាពិសេសសម្រាប់ស៊ីទែនទឹក និងកន្លែងលាងដៃ"។



© Nicolas Axelrod / Ruom / CARE

> *"ពេលយើងសម្រេចចិត្តដំឡើងស៊ីទែនទឹកនេះ សាលាគ្មានប្រាក់ឬថវិកាទេ ដូច្នេះខ្ញុំក៏ទូរសព្ទទៅគណៈកម្មការទ្រទ្រង់សាលារៀន ហើយសុំឱ្យពួកគេទិញឈើខ្លះ និងជួលកម្មករម្នាក់ដែលចេះដំឡើងស៊ីទែនទឹក"។*

លោកម៉ៅ ដែលគិតថាការអប់រំមានសារៈសំខាន់បំផុតនោះបញ្ជាក់ថា ៖ "សូម្បីតែឥឡូវនេះក៏មានផែនការចាប់ផ្តើមសាងសង់ខ្លះដែរ"។

លោកម៉ៅ ដែលបានធ្វើគ្រូបង្រៀនរហូតបានក្លាយជានាយកសាលា ហាក់ដូចជាមានមោទនភាពណាស់ចំពោះការប្តេជ្ញាចិត្ត និងសមិទ្ធផលរបស់គណៈកម្មការទ្រទ្រង់សាលារៀនរបស់គាត់ ដែលបានជួយធ្វើឱ្យសាលារៀនក្លាយជាកន្លែងល្អប្រសើរសម្រាប់សិស្សគាត់។ [គាត់បញ្ជាក់ថា] ៖ "បើសាលាមិនស្អាតសិស្សក៏មិនមករៀនដែរ ដូច្នេះសាលាត្រូវតែស្អាត និងមានដំណើរការ"។

សាលារៀនរបស់គាត់ ជាឧទាហរណ៍មួយនៃអត្ថប្រយោជន៍របស់សមាជិកសហគមន៍ ដែលបានចូលរួមក្នុងអភិបាលកិច្ចសាលារៀនរបស់ពួកគេ និងផលដែលការចូលរួមនេះអាចមានលើការអប់រំរបស់កុមារនៅតំបន់ដាច់ស្រយាលនៃប្រទេសកម្ពុជា។

**These activities are part of the *School Governance* project, which is supported by the Capacity Development Partnership Fund.**

សហភាពអឺរ៉ុប

SWEDEN

unicef

មូលនិធិភាពជាដៃគូសម្រាប់អភិវឌ្ឍសមត្ថភាពវិស័យអប់រំ (CDPF)

© CARE Cambodia, September 2016